44/4

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

**សំណុំរឿងព្រហ្មទណ្ឌ**
លេខ ៖ ៣១៩
ចុះថ្ងៃទី០៧-០៤-២០១១
**សាលដីកា**
លេខ ៖ ៣៦គ្រ.ll
ចុះថ្ងៃទី២២-០៣-២០១២

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍ភ្នំពេញ

បានបង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះ ក្តីដែលប្រកាសអោយប្រើតាមក្រឹត្យ-ច្បាប់ លេខ ០៦ក្រ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ បានបើកសវនាការជាអសាធារណៈនៅសាលសវនាការសាលាឧទ្ធរណ៍នាថ្ងៃទី ០៩-០៣-២០១២ ដោយមានសមាសភាពដូចខាងក្រោម ៖

**សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ**

- ឯកឧត្តម [redacted] ជាប្រធានក្រុមប្រឹក្សា
- ឯកឧត្តម [redacted] ជាចៅក្រមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

- លោក [redacted]

**ក្រឡាបញ្ជីសវនាការ**

- លោកស្រី [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ ៣១៩ ចុះថ្ងៃទី ០៧-៤-២០១១ ដែលមាន ៖

-ជនជាប់ចោទឈ្មោះ [redacted] ធីរៈ ហៅ វិន ភេទប្រុសអាយុ២០ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរជាងពេងពុម្ព កើតនៅភូមិកោះឃ្លោក ឃុំកំពង់ត្រាចខាងកើត ស្រុកកំពង់ត្រាច ខេត្តកំពត មានទីលំនៅមុនពេល [redacted] ខណ្ឌទួលគោក រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ប)ម្តាយឈ្មោះ [redacted](រ) រៀនថ្នាក់ទី១០ នៅលីវ ទោសពីមុនគ្មាន។

-ឃាត់ខ្លួនថ្ងៃទី ២២-១១-២០០៩ និងឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៣០១៩គ.ព្រ ចុះថ្ងៃទី ២៥-១១-២០០៩។

-មេធាវីឈ្មោះ [redacted] សុជាតិ ការពារឲ្យជនជាប់ចោទ ។





Scanned with CamScanner

**-ជាប់ចោទពីបទ:** **រួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ** ប្រព្រឹត្តនៅផ្ទះសំណាក់ចេកមាស (ក្រោយសាលាបាក់ទូក) ខណ្ឌ៧មករា រាជធានីភ្នំពេញកាលពីថ្ងៃទី២០ខែវិច្ឆិកា ឆ្នាំ២០០៩បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ចារុនី** ភេទស្រីអាយុ៥០ឆ្នាំ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិ[redacted] ស្រុកគីរីវង្ស ខេត្តតាកែវ មុខរបរស់អាងការ ឪពុកឈ្មោះ [redacted](ស) ម្តាយឈ្មោះ [redacted](រ) ប្តីឈ្មោះ [redacted]។

**<u>អំពីអង្គហេតុ ៖</u>**

កាលពីថ្ងៃទី ២០-១១-២០០៩ វេលាប្រហែល៦ល្ងាច ជនរងគ្រោះឈ្មោះ [redacted] **ខ័ន្ធយ៉ា** ភេទស្រី អាយុ១៥ឆ្នាំ បានទូរស័ព្ទហៅឈ្មោះ [redacted] **ទីរះហៅ ទិន**ភេទប្រុស អាយុ២០ឆ្នាំ ឲ្យមកយកខ្លួននៅកន្លែងចេនឡា ពេលនោះឈ្មោះ [redacted] **ទីរះ**ក៏បានជិះម៉ូតូឌុបមកយកឈ្មោះ **យ៉ា** រួចនាំគ្នាទៅហូបបាយនៅមុខចេនឡា បន្ទាប់មកបានទៅរកជួលផ្ទះសំណាក់ដេក បន្ទាប់ពីរកផ្ទះសំណាក់ដេកហើយ គឺផ្ទះសំណាក់ចេកមាស (ក្រោយសាលាបាក់ទូក) រួចក៏បានទុកឥវ៉ាន់នៅទីនោះ រួចក៏នាំគ្នាជិះម៉ូតូទៅញ៉ាំបាយ និងសាច់គោអាំងនៅស្តុបទេពជន រួចហើយក៏នាំគ្នាទៅគេងផ្ទះសំណាក់វិញ នៅយប់នោះឈ្មោះ [redacted] **ទីរះ**ក៏បានដេកគ្រែមួយពីរនាក់ជាមួយឈ្មោះ **យ៉ា** (ជនរងគ្រោះ) ហើយបានរួមរ័កជាមួយឈ្មោះ **យ៉ា** ពីរដង លើកទីមួយនៅវេលាម៉ោងប្រហែល២ លើកទី២ វេលាម៉ោងប្រហែល ៥ភ្លឺ មុនពេលរួមរ័កឈ្មោះ **យ៉ា** បានដោះសំលៀកបំពាក់ខ្លួនឯង ហើយពេលរួមរ័កនោះឈ្មោះ **យ៉ា**ពុំមានស្រែកអ្វីទេ។ ពេលរួមរ័កនោះឈ្មោះ **ទីរះ**បានដាក់ប្រដាប់ភេទចូលទៅក្នុងប្រដាប់ភេទរបស់ឈ្មោះ **យ៉ា**ទាំងពីរលើក។ លុះដល់ថ្ងៃទី២១-១១-២០០៩ វេលាម៉ោង១០ព្រឹកឈ្មោះ **យ៉ា** បានទូរស័ព្ទហៅឈ្មោះ **ទីរះ**ឲ្យទៅជួបនៅម្តុំផ្សារថ្មី ពេលនោះទៅដល់សមត្ថកិច្ចចាប់ខ្លួនតែម្តង។

**-បានឃើញ សេចក្តីសម្រេចរបស់សាលាដំបូងរាជធានីភ្នំពេញ សម្រេចតាមអំណាចសាលក្រមព្រហ្មទណ្ឌលេខ: ១៥០ (ក្រ១) ចុះថ្ងៃទី ២១-១២-២០១០ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖**

១-ផ្តន្ទាទោសឈ្មោះ [redacted] **ទីរះ** ហៅ **ទិន** ភេទប្រុស អាយុ២០ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ៥ឆ្នាំ (ប្រាំឆ្នាំ) ពីបទ: រួមភេទជាមួយអនីតិជនអាយុក្រោម ១៥ឆ្នាំប្រព្រឹត្តនៅចំណុចផ្ទះសំណាក់ចេកមាស (ក្រោយសាលាបាក់ទូក) ខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៩ តាមមាត្រា ៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

២-បង្គាប់ឲ្យឈ្មោះ [redacted] **ទីរះ** ហៅ **ទិន** បង់ប្រាក់សំណងជម្ងឺចិត្តចំនួន៤.០០០.០០៛ (បួនលានរៀល) ឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ចារុនី**។ ការទាមទារលើសពីនេះត្រូវច្រានចោល។

៣-សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ០៩-១២-២០១០និងប្រកាសជាសាធារណៈនៅថ្ងៃទី២១-១២-២០១០ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ទីរៈ ហៅ ទិន មេធាវីការពារជនជាប់ចោទ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចារុនី និងជនរងគ្រោះឈ្មោះ [redacted] ខ័ន្ធយ៉ា បើកផ្លូវប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

**-ឃើញ** សេចក្តីសុំប្តឹងឧទ្ធរណ៍លេខ ៩៥២ ចុះថ្ងៃទី ២៨-១២-២០១០ របស់ ជនជាប់ចោទឈ្មោះ [redacted] ទីរៈ សុំប្តឹងឧទ្ធរណ៍ និងសាលក្រមព្រហ្មទណ្ឌលេខ ១៥០ ក្រ១ ចុះថ្ងៃទី ២១-១២-២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសំរេចសាលក្រមទាំងមូល។

**-ឃើញ** របាយការណ៍រឿងព្រហ្មទណ្ឌ របស់ចៅក្រមរបាយការណ៍នៃសាលាឧទ្ធរណ៍។

**-ឃើញ** សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការសាលាឧទ្ធរណ៍។

**នាពេលសវនាការ**

| | |
|---|---|
| -ជនជាប់ចោទឈ្មោះ [redacted] ទីរៈ | (វត្តមាន) |
| -មេធាវីឈ្មោះ [redacted] សុជាតិ ការពារឲ្យជនជាប់ចោទ | (វត្តមាន) |
| -ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចារុនី | (អវត្តមាន) |
| -ឪពុកជនរងគ្រោះឈ្មោះ [redacted] សួម | (វត្តមាន) |
| -ជនរងគ្រោះឈ្មោះ [redacted] ខ័ន្ធយ៉ា | (វត្តមាន) |
| -មេធាវីឈ្មោះ [redacted] ណាត ការពារសិទ្ធិឲ្យជនរងគ្រោះ | (វត្តមាន) |

ប្រធានក្រុមប្រឹក្សាជំនុំជម្រះអានរបាយការណ៍សង្ខេបរឿង

-ជនជាប់ចោទឈ្មោះ [redacted] ទីរៈ បានឆ្លើយថាៈ ខ្លួនមិនបានប្រព្រឹត្តបទចាប់រំលោភដូចការចោទប្រកាន់ទេ ព្រោះតាមការពិនិត្យ និងធ្វើកោសល្យវិច័យ គឺលទ្ធផលបញ្ជាក់ថានៅល្អ ។ សំណូមពរ សុំឲ្យតុលាការលើកលែងទោសឲ្យខ្លួនផង ។

-ជនរងគ្រោះឈ្មោះ [redacted] ខ័ន្ធយ៉ា បានឆ្លើយថាៈ ឈ្មោះ វិន ហៅ [redacted] វីរៈ ពិតជាបានចាប់រំលោភខ្លួនមែន ចំនួន ៤ដង ពេលនោះខ្លួននៅក្មេងទើបតែមានអាយុ ១៥ឆ្នាំ ។ សំណូមពរ សុំឲ្យតុលាការពិចាណាតាមច្បាប់ ។

-ក្រឡាបញ្ជីអានចម្លើយជនរងគ្រោះនៅប៉ូលីស និងចៅក្រមស៊ើបសួរ ។

**សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ** :

ជនល្មើសពិតជាបានចាប់រំលោភប្រាកដមែន សាលក្រមរបស់សាលាដំបូងរាជធានីភ្នំពេញ សម្រេចមានលក្ខណៈត្រឹមត្រូវហើយ សុំតម្កល់សាលក្រមទុកជាបានការដដែល ។

-មេធាវីឈ្មោះ [redacted] សុជាត ការពារសិទ្ធិឲ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថាៈ កូនក្តីខ្លួនបានបដិសេធនៅចៅក្រមស៊ើបសួរ ដោយលទ្ធផលបានបញ្ជាក់ថានៅល្អ ។ សំណូមពរ សូមក្រុមប្រឹក្សាពិចារណាតាមមាត្រា ៣៨ ត្រូវមានវិមតិសង្ស័យលើកូនក្តីខ្លួន និងសុំលើក លែងចោទប្រកាន់ ។



Scanned with CamScanner

-មេធាវី [redacted]ឈោត ការពារឲ្យជនរងគ្រោះបានធ្វើសេចក្តីសន្និដ្ឋានថា៖ ជនជាប់ចោទឈ្មោះ [redacted] វិរៈ អាយុ ២០ឆ្នាំ ឯកូនក្តីខ្លួន [redacted] ខន្ធ័យ៉ា ទើបមានអាយុ ១៨ឆ្នាំប៉ុណ្ណោះ ដូច្នេះជនជាប់ចោទពិតជាបានរួមភេទមែន សូមក្រុមប្រឹក្សាពិចារណាតាមច្បាប់ និងសុំតម្កល់សាលក្រមរបស់សាលាដំបូងដដែល ។

-ក្រោយពីបានស្តាប់របាយការណ៍រឿង

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនរងគ្រោះ

-ក្រោយពីបានពិនិត្យភស្តុតាងឯកសារនានា

-ក្រោយពីបានពិភាក្សា និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ។

**សាលាឧទ្ធរណ៍**

**យល់ឃើញថា**

១-បណ្តឹងឧទ្ធរណ៍លេខ ៩៥២ ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ២០១០របស់ជនជាប់ចោទឈ្មោះ [redacted]ទីរៈ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១៥០ ក្រ១ ចុះថ្ងៃទី២១-១២-២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ធ្វើឡើងក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍អាចលើករឿងនេះ យកមកជំនុំជម្រះបានតាមច្បាប់។

២-តាមការសួរដេញដោល ឃើញថាមានភស្តុតាង និងពិរុទ្ធភាព គ្រប់គ្រាន់ដាក់ បន្ទុកលើជនជាប់ចោទឈ្មោះ [redacted] វីរៈ ហៅ វិត ភេទប្រុស អាយុ ២០ឆ្នាំ ពីបទ រួមភេទជាមួយអនិតិជនអាយុក្រោម ១៥ឆ្នាំ ប្រព្រឹត្តនៅចំណុចផ្ទះសំណាក់ចេកមាស ខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៩ តាមមាត្រា ៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើផ្លូវភេទ ។

៣-សាលក្រមព្រហ្មទណ្ឌលេខ ១៥០ ក្រ១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ហើយ គប្បីសាលាឧទ្ធរណ៍ តម្កល់សាលក្រមព្រហ្មទណ្ឌនេះ ទុកជាបានការពេញទាំងមូល។

**ហេតុដូច្នេះ**

**ចនិច្ឆ័យសេចក្តី**

១-ទទួលបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទឈ្មោះ [redacted] ទីរៈ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១៥០ ក្រ១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការពេញទាំងមូល។



Scanned with CamScanner

៣-សាលដីកានេះជំនុំជម្រះនៅថ្ងៃទី០៩ ខែមិនា ឆ្នាំ២០១២ ចំពោះមុខមេធាវីការពារជនជាប់ចោទ, ជនជាប់ចោទ , មេធាវីការពារសិទ្ធិឲ្យជនរងគ្រោះ , កំបាំងមុខដើមបណ្ដឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈនៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០១២ ។ បើកផ្លូវតវ៉ាក្នុងកំណត់ច្បាប់ ។

**ក្រឡាបញ្ជី**
ហត្ថលេខា [redacted]

**ចៅក្រមប្រឹក្សា**
ហត្ថលេខា [redacted], [redacted]

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**
ហត្ថលេខា [redacted]

---

បានឃើញ
**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**
[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ ថ្ងៃទី 03 ខែ 04 ឆ្នាំ២០១២
**ក្រឡាបញ្ជី**
[redacted]